ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

**តុលាការកំពូល**
**សំណុំរឿងព្រហ្មទណ្ឌ**
**លេខ: ២៨**
**ចុះថ្ងៃទី០៩-០៦-៩៩**
**សាលដីកាលេខ៖១៦**
**ចុះថ្ងៃទី២៨-០៧-៩៩**

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ៖

១- ឯកឧត្តម... ប្រធាន
២- លោក... ចៅក្រម
៣- លោក... ចៅក្រម
៤- លោក... ចៅក្រម
៥- លោក...... ចៅក្រមរបាយការណ៍

ក្រឡាបញ្ជី
លោក...
តំណាងមហាអយ្យការ
លោក...ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះ លើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៩៥ ចុះថ្ងៃទី០៨ -០៥-១៩៩៨ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល និង សំណុំរឿងព្រហ្មទណ្ឌលេខ២៨ ចុះថ្ងៃទី០៩-០៦-១៩៩៨ របស់តុលាការកំពូល។

-ជនជាប់ចោទឈ្មោះ **ញផ** (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៦ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិរាំង ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ ឪពុកឈ្មោះ...ម្តាយឈ្មោះ...ប្រពន្ធឈ្មោះ... មានកូន០៣នាក់។

-មេធាវី គ្មាន

-ត្រូវចោទពីបទៈ សម្លាប់មនុស្សដោយចេតនាមានអាវុធ ប្រព្រឹត្តនៅខេត្តកំពង់ស្ពឺកាលពីថ្ងៃទី១២-០២-១៩៨០។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ**យប**(ម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ ៤៤ឆ្នាំ ជាតិខ្មែរ សព្វថ្ងៃនៅភូមិរាំង ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

-មេធាវី លោក...

-តាមកំណត់ហេតុលេខ៨៧ ចុះថ្ងៃទី០៧-១០-១៩៩៦ របស់អយ្យការអមតុលាការខេត្តកំពង់ស្ពឺថាៈ នាង **យហ** បានឆ្លើយថាកាលពីខែមិនចាំ ឆ្នាំ ១៩៨០ ម៉ោង៧ល្ងាចប្តីខ្លួនឈ្មោះ **អប** មកពីធ្វើការនៅឃុំជង្រុក មកដល់ផ្ទះឈ្មោះ **ឡឆ** អ្នកនៅក្នុងផ្ទះសួរថាពូមកដល់ស្មើម៉ាន ប្តីខ្លួនថាស្ទាត់ណាស់សុំបាញ់មួយគ្រាប់ហើយ ប្តីខ្លួនក៏បាញ់មួយគ្រាប់ឡើងលើ។ មួយសន្ទុះឈ្មោះ **ញផ** មកដល់កន្លែងបាញ់ហើយសួរថា អ្នកណាបាញ់អម្បាញ់វិញ ប្តីខ្ញុំថាខ្ញុំលោក ពេលនោះលោក **ញផ** ថាបាញ់មានដឹងប្រជាជនឮឬទេ។ ប្តីខ្លួនថាខ្ញុំបាញ់ហួសហើយហើយ **ញផ** ក៏បាញ់ប្តីខ្លួន តែម្តង អស់ចំនួនពីរគ្រាប់ត្រូវត្រង់សៀតផ្កាឆ្វេងហើយមួយគ្រាប់ទៀតត្រូវត្រង់ទ្រូងធ្លាយទៅខ្នង ធ្វើឱ្យប្តីខ្លួនដួលស្លាប់នៅនឹងកន្លែង។ ពេល **ញផ** បាញ់ប្តីខ្លួនមានឈ្មោះ **ឡអ, ឡភ, តឆ**,ម្ចាស់ផ្ទះ និង **ហស** ជាអ្នកឃើញ **ញផ** បាញ់។

-បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការខេត្តកំពង់ស្ពឺថាៈ ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទចម្លើយសាក្សី និង

លិខិតបញ្ជាក់មរណភាពអយ្យការ នៅតែរក្សាការចោទប្រកាន់ ព្រោះឈ្មោះ **ញផ** នេះ តុលាការពុំទាន់បានកាត់ទោសនៅឡើយទេគ្រាន់តែសមត្ថកិច្ចបានឃុំខ្លួន រួចក៏ដោះលែងទៅ។ ដូច្នេះសូមតុលាការ សម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ **ញផ** ទៅតាមច្បាប់។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៣៤ចុះថ្ងៃទី២០-០៨-១៩៩៧ របស់តុលាការខេត្តកំពង់ស្ពឺ ដែលបានសម្រេច

១-លើកលែងចោទប្រកាន់លើឈ្មោះ **ញផ** ដោយឈ្មោះ **ញផ** ត្រូវបានដោះលែងជាស្ថាពរ តាមលិខិតគ្មាន លេខចុះថ្ងៃទី០៦-១២-១៩៩៤ រួចហើយចាប់ពីថ្ងៃនេះតទៅ។

២-ឱ្យឈ្មោះ **ញផ** សងជំងឺចិត្តដល់គ្រួសាររងគ្រោះឈ្មោះ**យប** ចំនួន ២.000.000រៀល(ពីរលានរៀល) សំណើលើសពីនេះបដិសេធចោល ។

៣-ឱ្យអភិបាលខេត្តកំពង់ស្ពឺប្រគល់ប្រាក់ ៥00.000 រៀល(ហាសិបម៉ឺនរៀល) ឱ្យទៅឈ្មោះ **យហ** ចាប់តាំងពីថ្ងៃនេះតទៅ សំណើលើសពីនេះបដិសេធចោល។

៤-សាលក្រមនេះជំនុំជម្រះជាសាធារណៈចំពោះគូក្តី បើកផ្លូវឧទ្ធរណ៍ពីរខែតាមច្បាប់កំណត់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៥ ចុះថ្ងៃទី២០-០៨-១៩៩៧ របស់ឈ្មោះ **យហ** ដែលប្តឹងតវ៉ាពីសាលក្រម លេខ៣៤ ចុះថ្ងៃទី២០-០៨-១៩៩៧ របស់តុលាការខេត្តកំពង់ស្ពឺ លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០-៨-១៩៩៧ របស់ដើមបណ្តឹង ឈ្មោះ **យហ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់។

២-បដិសេធសាលក្រមលេខ៣៤ ចុះថ្ងៃទី២០-០៨-៩៧ របស់តុលាការខេត្តកំពង់ស្ពឺចោលជាអសារបង់។

៣-សម្រេចរំលត់បណ្តឹងអាជ្ញាដោយផុតអាជ្ញាយុកាល លើឈ្មោះ **ញផ** ពីបទសម្លាប់មនុស្សដោយចេតនា ប្រព្រឹត្តនៅភូមិរាំង ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៦-០២-១៩៨០ តាមប្រការ៧(ក) នៃក្រឹត្យច្បាប់លេខ០២ករ ចុះថ្ងៃទី១៥ -០៥-១៩៨០ ។

-បានឃើញសាដីកាព្រហ្មទណ្ឌលេខ២៦០ ចុះថ្ងៃទី២៧-១១-១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច៖

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០-០៨ - ១៩៩៧ របស់ឈ្មោះ **យប** ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមលេខ៣៤ ចុះថ្ងៃទី២០-០៨-៩៧ របស់តុលាការខេត្តកំពង់ស្ពឺទុកជាបានការ លើកលែងតែចំណុចទី១ នៃសាលក្រមបដិសេធចោល ហើយសម្រេចជាថ្មីថា រាល់បណ្តឹងអាជ្ញាលើឈ្មោះ **ញផ** ពីបទចោទប្រកាន់ធ្វើមនុស្សឃាតដោយចេតនា តាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅភូមិរាំង ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៤-០២-៨០។

៣-សាលដីកានេះ ជំនុំជម្រះនិងប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងកំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងទាស់ និងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្ដឹងសាទុក្ខលេខ២១ចុះថ្ងៃទី១៨-០៥-១៩៩៨ របស់អ្នកស្រី **យហ** ដែលប្ដឹងពីសាលដីកាព្រហ្មទណ្ឌលេខ២៦០ ចុះថ្ងៃទី២៧-១១-១៩៩៧ របស់សាលាឧទ្ធរណ៍លើសេចក្ដីសម្រេចទាំងមូល។

-បានឃើញសារណា ចុះថ្ងៃទី១៩-០៦-១៩៩៨របស់អ្នកស្រី **យហ** ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញលិខិតបង្គាប់ឱ្យឈ្មោះ **ញផ** ចុងបណ្ដឹងសាទុក្ខ ធ្វើសារណាតបពីសារណារបស់អ្នកស្រី **យហ** ហើយឈ្មោះនេះបានទទួលនៅថ្ងៃទី២៣-១០-៩៨ រួចហើយប៉ុន្ដែពុំបានឆ្លើយតបតាមកំណតច្បាប់ទេ។

-បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖

១-បណ្ដឹងសាទុក្ខរបស់ឈ្មោះ **យហ** ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះមកពិនិត្យពិចារណា។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៩៥ ចុះថ្ងៃទី៨-០៥-៩៨របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

-បានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ**យហ** ថា៖ ឈ្មោះ **ញផ** ពិតជាបានសម្លាប់ប្ដីនាងខ្ញុំមែន នាងខ្ញុំសុំឱ្យតុលាការ មេត្ដាជួយឱ្យរដ្ឋអំណាចថ្នាក់ខេត្ត ឬតុលាការខេត្តធ្វើជាអំណោយដល់ប្ដីនាងខ្ញុំព្រោះកន្លងមកថ្នាក់ខេត្តស្រុក ធ្វើអំណោយដែរ តែនាងខ្ញុំពុំបានទទួលហើយតុលាការខេត្តសម្រេចសំណងតិចតួចមិនសមនឹងអំពើរបស់ **ញផ** សម្លាប់ប្ដីនាងខ្ញុំឡើយ។

-តំណាងមហាអយ្យការ ពុំមានអ្វីបន្ថែមទៀតទេ សូមរក្សាសេចក្ដីសន្និដ្ឋាននៅដដែល។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២១ ចុះថ្ងៃទី១៨-០៥-១៩៩៨ របស់អ្នកស្រី **យហ** ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី។

-យល់ឃើញថា បទល្មើសនេះកើតឡើង នៅថ្ងៃ១២ ខែកុម្ភៈ ឆ្នាំ១៩៨០ ហើយអយ្យការអមតុលាការខេត្តកំពង់ស្ពឺ ទើបតែធ្វើការចោទប្រកាន់ជនល្មើសឈ្មោះ **ញផ** ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៩៧ ពីបទធ្វើមនុស្សឃាតដោយចេតនាមានអាវុធ ដូច្នេះបទល្មើសនេះប្រព្រឹត្តកន្លងទៅអស់រយៈពេលជាង១៧ឆ្នាំ ហើយពុំមាននីតិវិធីតុលាការទៀត ឃើញថាការដែលឈ្មោះ **ញផ** បានប្រព្រឹត្តកាលពីឆ្នាំ១៩៨០ មកចោទប្រកាន់នៅឆ្នាំ១៩៩៧ នោះគឺផុតអាជ្ញាយុកាសនៃបទល្មើសហើយ។

-យល់ឃើញថា ទោះបីអាជ្ញាយុកាល នៃបទល្មើសបានកន្លងផុតទៅហើយក្តី ប៉ុន្តែព្យសនៈកម្ម ដែលបណ្តាលមកពីអំពើល្មើសមានពិតប្រាកដ ហើយដើមបណ្តឹងរដ្ឋប្បវេណី ក៏បានប្តឹងតវ៉ាជាបន្តបន្ទាប់ដូច្នេះ តុលាការអាចសម្រេចអំពីសំណងរដ្ឋប្បវេណី។

-យល់ឃើញថា តុលាការថ្នាក់ក្រោមពុំបានសម្រេចបង្គាប់ឱ្យដាក់គុកបង្ខំដល់រូកាយ ក្នុងករណីជនល្មើសរឹងរូសពុំព្រមសងប្រាក់ធនទណ្ឌដូច្នេះតុលាការ

កំពូល សម្រេចបន្ថែមដាក់គុកបង្ខំដល់រូបកាយ តាមច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងករណីឈ្មោះ **ញូផ** រឹងរូបពុំព្រមសងប្រាក់ធនទណ្ឌគ្រប់ចំនួន។

-យល់ឃើញថា ជនជាប់ចោទបានទទួលលិខិតបង្គាប់ឱ្យ ធ្វើសារណាហើយ ប៉ុន្តែពុំបាន ធ្វើសារណាជូនមកតុលាការកំពូលទេដូច្នេះ តុលាការកំពូលជំនុំជម្រះរឿងនេះ កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៩៤ ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះ មុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ

-ទទួលបណ្តឹងសាទុក្ខលេខ២១ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៨ របស់អ្នកស្រី **យហ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៩៥ ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

៣-បង្គាប់ឱ្យដាក់គុកបង្ខំដល់រូបកាយ តាមច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌក្នុងករណីជនល្មើសរឹងរូស ពុំព្រមសងប្រាក់ធនទណ្ឌ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៩។